គណៈកម្មការពលករ
COMITE VIE OUVRIERE
ព្រះសហគមន៍កាតូលិកភ្នំពេញ
VICARIAT APOSTOLIQUE DE PHNOM PENH

**សង្ខេបព័ត៌មាន**
**7/2019**

## អង្គការ GIZបន្តជួយលើកកំពស់វិស័យកាត់ដេរនៅប្រទេសកម្ពុជា

អង្គការ GIZ បានផ្តល់ជំនួយគាំទ្រដល់ក្រសួងការងារដើម្បីលើកកំពស់វិស័យវាយនភ័ណ្ឌ និងកាត់ដេរនៅកម្ពុជា តាមរយៈគម្រោងមួយ “ ការពង្រឹងនិរន្តភាពវិស័យវាយនភ័ណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី” ។

លោក ងុយ រិទ្ធ អនុរដ្ឋលេខាធិការនៃក្រសួងការងារបានលើកឡើងនេះ ជាគម្រោងទី២ របស់ GIZ ដែលនឹងផ្តល់ការគាំទ្រលើផ្នែកហិរញ្ញវត្ថុ និងសុខភាព និងសមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្រ្តីដែលធ្វើការក្នុងវិស័យវាយនភ័ណ្ឌ និងកាត់ដេរ។

ក្រសួងការងារ និងអង្គការ GIZ បានចុះហត្ថលេខាយោគយល់គ្នា កាលពីថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៩ ដែលគម្រោងនេះមានរយៈពេល៣ឆ្នាំ ( ពីឆ្នាំ២០១៩ ដល់ ២០២១)។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងអំណរគុណដល់អង្គការ GIZ និងរដ្ឋាភិបាលអាល្លឺម៉ង់ដែលតែងតែផ្តល់ការគាំទ្រទាំងថវិកាក៏ដូចជាអ្នកជំនាញបច្ចេកទេសជួយដល់កម្ពុជាពិសេសវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

គម្រោង “ពង្រឹងនិរន្តភាព វិស័យវាយនភ័ណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី” (GIZ FABRIC) នេះមានថវិកាសរុបចំនួន ៦លានអឺរ៉ូ សម្រាប់អនុវត្តន៍លើប្រទេសបង់ក្លាដេស កម្ពុជា ចិន មីយ៉ាន់ម៉ា ប៉ាគីស្ថាន និងវៀតណាម៕

ថ្មីៗ 12/7/2019

## កម្មករ២នាក់ស្លាប់និង៣១នាក់របួសដោយសារក្រឡាប់ឡាននៅស្វាយរៀង

កម្មករ- កម្មការិនី២នាក់បានស្លាប់និងកម្មករ៣១នាក់ទៀតបានរងរបួសក្នុងគ្រោះថ្នាក់ចរាចរណ៍ដោយរថយន្តដែលពួកគេជិះបានក្រឡាប់នៅភូមិកំពង់រទេះ ឃុំពពែត ស្រុកស្វាយទាប ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩នេះ។

នេះបើតាមលោក កឹង យនស្នងការខេត្តស្វាយរៀង

លោកស្នងការប្រាប់សារព័ត៌មានថ្មីៗតាមទូរស័ព្ទថាកម្មការិនីទាំង៣១នាក់ដែលរបួសនោះត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យហើយ។

ថ្មីៗ 30/7/2019

RFA 30/7/19

BP 123 **cvo@catholiccambodia.org** **023 69 666 00** Google Maps (FJT)
R28, rue rongrœung 1 - Phum Toul pongro - Sangkat Chaomchao - Khan Posenchey - PHNOM PENH